## វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
## មុខវិជ្ជាស្រាវជ្រាវអប់រំ
## ឆ្នាំទី៣ ឆមាសទី១

# មេរៀនទី៤៖ ការកំណត់ប្រធានបទស្រាវជ្រាវ

Identifying Research Topic

## I. បញ្ហានៃការស្រាវជ្រាវ

- យោងតាម នេត(២០១៧) បញ្ហាស្រាវជ្រាវ គឺជាបញ្ហា កង្វល់ ឬការជជែកវែកញែកទូទៅមួយ ដែលនឹងត្រូវបានដោះស្រាយនៅក្នុងការស្រាវជ្រាវដោយការសម្រួចឬផ្តោតក្លាយទៅជាប្រធានបទនោះ។
- បញ្ហាស្រាវជ្រាវ គឺសំដៅលើបញ្ហាជាក់លាក់ ការលំបាក ឬគម្លាតនៃចំណេះដឹងណាមួយ ដែលអ្នកស្រាវជ្រាវមានបំណងដោះស្រាយតាម រយៈការសិក្សាអំពីបញ្ហានោះ។
- បញ្ហាស្រាវជ្រាវជាមូលដ្ឋានគ្រឹះនៃគម្រោងស្រាវជ្រាវ និងនាំអោយអ្នកស្រាវជ្រាវបង្កើតបាននូវសំណួរសម្មតិកម្ម និងវិធីសាស្ត្រស្រាវជ្រាវ។
- បញ្ហាស្រាវជ្រាវគឺជាសំណួរចម្បងដែលនាំទៅរកដំណើរការស្រាវជ្រាវ និងបង្ហាញអំពីគោលបំណងព្រមទាំងលទ្ធផលនៃការសិក្សា។
- បញ្ហានៃការស្រាវជ្រាវ (Research Problem) គឺជាបញ្ហា ឬសំណួរ ដែលកើតមាននៅក្នុងជីវិតសង្គម អប់រំ ឬវិទ្យាសាស្ត្រ ដែលមិនទាន់មានចម្លើយច្បាស់លាស់ ហើយត្រូវការការសិក្សា ឬស្រាវជ្រាវដើម្បីស្វែងយល់ និងដោះស្រាយ។

## II. ការកំណត់បញ្ហាស្រាវជ្រាវ




III. **ការកំណត់ប្រធានបទស្រាវជ្រាវ** ( Identifying Action Research Topic )

យោងតាម នេត ( ២០១៧ ) ប្រធានបទស្រាវជ្រាវ ( Research topic ) គឺជាគោលបំណងឬសាច់រឿងទូទៅដែលនឹងត្រូវដោះស្រាយ ឬរុករកដោយការសិក្សាស្រាវជ្រាវនោះ។

**១.ការស្រាវជ្រាវបែបបរិមាណវិស័យ** ( Quantitative Research )

ការកំណត់ប្រធានស្រាវជ្រាវបែបបរិមាណវិស័យ អ្នកស្រាវជ្រាវត្រូវកំណត់ជាតុសំខាន់ៗនីមួយៗអោយបានច្បាស់លាស់មានដូចជា៖

- អថេរសំខាន់ៗ
  - អថេរឯករាជ្យ ឬអថេរហេតុ
  - អថេរមិនឯករាជ្យ ឬអថេរផល
- ឃ្លាបង្ហាញទំនាក់ទំនងរវាងអថេរ
  - ឥទ្ធិពលនៃការប្រើប្រាស់...ទៅលើ...
  - ប្រសិទ្ធភាពនៃការប្រើប្រាស់...ដើម្បីកាត់បន្ថយ/លើកកម្ពស់/កែលម្អ...
  - ទំនាក់ទំនងរវាង...និង...
  - ការលើកកម្ពស់/ការកាត់បន្ថយ/ការកែលម្អ...តាមរយៈការប្រើប្រាស់...
- សំណាក ឬក្រុមគោលដៅ
- ឈ្មោះវិធីសាស្ត្រស្រាវជ្រាវ ( ជាជម្រើស )
  - ការស្ទង់មតិ

- ការពិសោធ
- ការសិក្សាបែបទំនាក់ទំនង។ល។

**ឧទាហរណ៍១**




**ឧទាហរណ៍២**




**ឧទាហរណ៍៣**




ឧទាហរណ៍៤




## ២.ការស្រាវជ្រាវបែបគុណវិស័យ (Qualitative Research)

ការកំណត់ប្រធានស្រាវជ្រាវបែបគុណវិស័យអ្នកស្រាវជ្រាវត្រូវកំណត់ធាតុសំខាន់ៗនីមួយៗ មានដូចជា៖

- ពាក្យគន្លឹះក្នុងប្រធានដែលត្រូវសិក្សា
- ប្រើប្រាស់កិរិយាសព្ទសកម្មបែបរៀបរាប់ដូចជា ស្វែង សិក្សា រៀបរាប់....។ល។
- ឈ្មោះវិធីសាស្ត្រស្រាវជ្រាវ
  - ករណីសិក្សា
  - ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ
  - ការស្រាវជ្រាវបែបទ្រឹស្តីបឋម។ល។

ឧទាហរណ៍

ឧ.១ ការស្វែងយល់ពីឥរិយាបថរបស់គរុសិស្ស ចំពោះការសិក្សាមុខវិជ្ជាស្រាវជ្រាវអប់រំ

៤.២ ការសិក្សាពីទស្សនៈរបស់គរុសិស្សពីការអនុវត្តកញ្ចប់អំណានថ្នាក់ដំបូង

៤.៣ ការរៀបរាប់ពីបទពិសោធន៍របស់គរុនិស្សិត ក្នុងការរៀបចំរបាយការណ៍ស្រាវជ្រាវ

**ករណីសិក្សា៖** គរុនិស្សិត១២+ ៤ ឆ្នាំទី៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

## IV.**ប្រធានស្រាវជ្រាវដែលមានលក្ខណៈល្អ**

- ច្បាស់លាស់ និងសង្ខេបៈប្រធានបទត្រូវសរសេរឲ្យច្បាស់ ងាយយល់ ហើយមិនវែងឬស្មុគស្មាញពេក
- ពាក់ព័ន្ធនឹងបញ្ហាជាក់ស្តែង៖ ត្រូវផ្តែកលើបញ្ហាដែលកើតមានពិតៗ និងត្រូវការដោះស្រាយ
- មានសារៈសំខាន់៖ អាចផ្តល់អត្ថប្រយោជន៍ដល់វិទ្យាសាស្ត្រ សង្គម សាលារៀន ឬសហគមន៍
- អាចអនុវត្តបាន៖ សមរម្យនឹងពេលវេលា ថវិកា និងធនធានដែលអ្នកស្រាវជ្រាវមាន
- មិនទូលំទូលាយពេក ឬតូចចង្អៀតពេក៖ គួរតែមានវិសាលភាពសមរម្យ ដើម្បីងាយស្រួលក្នុងការសិក្សា
- អាចវាស់វែងនិងប្រមូលទិន្នន័យបាន៖ប្រធានបទត្រូវអាចរកទិន្នន័យនិងវិភាគបានតាមវិធីវិទ្យាសាស្ត្រ
- មានតម្លៃវិទ្យាសាស្ត្រ និងនវានុវត្តន៍៖ អាចបន្ថែមចំណេះដឹង ឬផ្តល់ទស្សនៈថ្មីៗ។

## ឯកសារយោង


1) Creswell, J. W., & Creswell, J. D. (2018). *Research design: Qualitative, quantitative, and mixed methods approaches* (5th ed.). SAGE Publications.
2) Fraenkel, J. R., Wallen, N. E., & Hyun, H. H. (2019). *How to design and evaluate research in education* (10th ed.). McGraw-Hill Education.
3) Kumar, R. (2019). *Research methodology: A step-by-step guide for beginners* (5th ed.). SAGE Publications.